# ការបំបែកពាក្យខ្មែរដែលមិនអាចសរសេរអស់នៅចុងបន្ទាត់
# ឬ
# របៀបសរសេរតផ្នែករបស់ពាក្យខ្មែរពីចុងខាងស្តាំនៃបន្ទាត់មួយ
# ទៅចុងខាងឆ្វេងនៃបន្ទាត់បន្ទាប់

ក្នុងការសរសេរអត្ថបទជាខ្មែរនៅលើក្រដាស ឬវាយអត្ថបទជាខ្មែរនៅក្នុងកុំព្យូទ័រ យើងអាចមានតម្រូវការសរសេរពាក្យមួយដោយបំបែកវាជាពីរផ្នែកគឺផ្នែកខាងដើមសរសេរនៅចុងខាងស្តាំនៃបន្ទាត់លើ ឯផ្នែកខាងចុងសរសេរនៅចុងខាងឆ្វេងនៃបន្ទាត់ក្រោមបន្ទាប់។

តាមការសង្កេតយើងដូចជាមិនទាន់មានវិធានវេយ្យាករណ៍ដែលកំណត់របៀបសរសេរតផ្នែករបស់ពាក្យខ្មែរពីចុងខាងស្តាំនៃបន្ទាត់មួយទៅចុងខាងឆ្វេងនៃបន្ទាត់បន្ទាប់នៅឡើយទេ។

ដើម្បីឱ្យអ្នកអានអានបានត្រឹមត្រូវតាមសំណួរនិងយល់បានត្រឹមត្រូវតាមន័យរបស់ពាក្យដែលត្រូវសរសេរតផ្នែកពីចុងខាងស្តាំនៃបន្ទាត់លើទៅចុងខាងឆ្វេងនៃបន្ទាត់ក្រោមបន្ទាប់ និងដើម្បីឱ្យមានឯកភាពក្នុងការបំបែកពាក្យ យើងគួរមានវិធានសម្រាប់ការបំបែកពាក្យឬការតផ្នែកនៃពាក្យ។

ខាងក្រោមនេះគឺជាយោបល់មួយចំនួនសម្រាប់ការបំបែកពាក្យខ្មែរដែលមិនអាចសរសេរអស់នៅចុងបន្ទាត់ ឬរបៀបសរសេរតផ្នែករបស់ពាក្យខ្មែរពីចុងខាងស្តាំនៃបន្ទាត់មួយទៅចុងខាងឆ្វេងនៃបន្ទាត់បន្ទាប់ ដោយយកតាមបទពិសោធក្នុងការរៀបចំអត្ថបទជាភាសាបារាំងនិងអង់គ្លេស៖

១-ប្រើវជ្ជសញ្ញាឬសហសញ្ញា (-) "Trait d'union"សម្រាប់តភ្ជាប់ផ្នែកទាំងពីររបស់ពាក្យ

២- វជ្ជសញ្ញាឬសហសញ្ញាត្រូវដាក់នៅចុងខាងស្តាំនៃបន្ទាត់លើ

៣-ត្រូវបំបែកពាក្យជាពីរផ្នែកដែលផ្សំដោយព្យាង្គ ពោលគឺមិនត្រូវបំបែកពាក្យមួយព្យាង្គជាពីរផ្នែកដើម្បីតទេ

ឧទាហរណ៍៖- ត្រូវបំបែកបែបនេះ៖ រកាំ/រកូស ការ/ងារ បដិ/សណ្ឋារកិច្ច

-មិនត្រូវបំបែកបែបនេះទេ៖ ស/ន្និដ្ឋាន បដិស/ណ្ឋារកិច្ច ប/ណ្តោយ ចា/យស្តា/ប់

៤-ត្រូវចៀសវាងការបំបែកដែលអាចឲ្យគេអានខុសសំណួររបស់ពាក្យ

ឧទាហរណ៍៖ មិនត្រូវបំបែកបែបនេះ៖ មី/នា ស្រ/វឹង ពេទ្យ/សាស្ត្រ វិទ្យា/ល័យ អ/ចិន្ត្រៃយ៍ ស/មានចិត្ត សមាន/ចិត្ត

៥- ក្នុងការតពាក្យផ្សំ មិនត្រូវបំបែកពាក្យបន្ថែមដើមឬពាក្យបន្ថែមចុង និងពាក្យឫសទេ

ឧទាហរណ៍៖ -មិនត្រូវបំបែកបែបនេះ៖ ការប៉ិន/ប្រសប់ តែអាចបំបែកបែបនេះ៖ ការ/ប៉ិនប្រសប់

-មិនត្រូវបំបែកបែបនេះ៖ ការចាំ/បាច់ តែអាចបំបែកបែបនេះ៖ ការ/ចាំបាច់

-មិនត្រូវបំបែកបែបនេះ៖ សេចក្តីថ្លៃ/ថ្នូរ តែអាចបំបែកបែបនេះ៖សេចក្តី/ថ្លៃថ្នូរ

៦-ចំពោះពាក្យដែលមានបីព្យាង្គឬច្រើនជាង គួរចៀសវាងការបំបែកពាក្យជាព្យាង្គដែលអាចឲ្យអានខុសសំណួរព្យាង្គបន្ដើរនិងព្យាង្គសង្កត់ក្នុងពាក្យ

ឧទាហរណ៍ៈ-គួរកុំបំបែកបែបនេះៈ រ/កាកោង   រ/លីងឈូក  រ/លីងរលោង

-គួរបំបែកបែបនេះៈ រកា/កោង   រលីង/ឈូក   រលីង/រលោង។

៧-បើមិនផ្ទុយនឹងវិធានទាំងឡាយខាងលើទេ នោះផ្នែកដែលនៅបន្ទាត់លើគួរឲ្យខ្លីជាងផ្នែកដែលនៅបន្ទាត់ក្រោម

ឧទាហរណ៍ៈ- គួរបំបែកបែបនេះៈ ការ/ធ្វើដំណើរ ជាជាងការបំបែកបែបនេះៈ ការធ្វើ/ដំណើរ

- គួរបំបែកបែបនេះៈ ការ/ផ្ទេរតំណែង  ជាជាងការបំបែកបែបនេះៈការផ្ទេរ/តំណែង

៨-កុំបំបែកពាក្យដែលជានាមឬគុណនាមអសាធារណ៍

ឧទាហរណ៍ៈ កុំបំបែក បារាំង សូវៀត អាមេរិក

៩-កុំបំបែកពាក្យកាត់ ពាក្យដែលជាអក្សរកាត់ និងអក្សរសង្ខេប

ឧទាហរណ៍ៈ កុំបំបែក ផ.ស.ស.  ស.ប.ស.ខ.  បា.សំ.ក្ល.  សំ.បា.ក្ល.

១០-កុំបំបែកចំនួនសរសេរជាលេខចេញពីឯកតាដែលសរសេរជាអក្សរកាត់

ឧទាហរណ៍ៈ កុំបំបែក ២ ០០០ ០០០៛  ៧៨គម  ៩០%

១១-កុំបំបែកចំនួនសរសេរជាលេខចេញពីនាមដែលនៅពីមុខវា

ឧទាហរណ៍ៈ កុំបំបែក មាត្រា១០  ប្រការ២  ឆ្នាំ២០១៨

១២-កុំបំបែកពាក្យដែលកំណត់ប្រើក្នុងគណិតវិទ្យា

ឧទាហរណ៍ៈ កុំបំបែក ត្រីកោណកខគ   បន្ទាត់កខ

១៣-បើជាពាក្យដែលសរសេរដោយមានវជ្ជសញ្ញា នោះត្រូវបំបែកដោយប្រើវជ្ជសញ្ញាដែលមានស្រាប់

ឧទាហរណ៍ៈ រលឹបរ-/ល  កុកស-/ក  (វចនានុក្រម)ខ្មែរ-/បារាំង  (មិត្តភាព) កម្ពុជា-/ចិន

១៤-កុំបំបែកពាក្យមួយនៅខាងចុងបន្ទាត់ បើផ្នែកបន្តរបស់វាត្រូវឆ្លងទៅទំព័រថ្មី។